**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ 08/2005 កបធ………

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០០៥

**សូមក្រាបថ្វាយបង្គំទូល**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**កម្មវត្ថុ** : សេចក្តីថ្វាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អំពីសេចក្តីស្នើច្បាប់ធម្មនុញ្ញ សំដៅកែសម្រួលកូរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងព្រឹទ្ធសភា ។

**យោង** : ព្រះរាជសារ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៥

ទូលព្រះបង្គំយើងខ្ញុំ ជាប្រធាន និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៥ ហើយបានឯកភាពលើកមតិដើម្បីក្រាបថ្វាយបង្គំទូលព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារដូចតទៅ ÷

១- សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ មានគោលដៅកែប្រែមាត្រា ៨៨ និងមាត្រា ១១១ ថ្មីនៃរដ្ឋធម្មនុញ្ញ ដើម្បីសម្រួលកូរ៉ុមប្រជុំរដ្ឋសភា និងព្រឹទ្ធសភា ដែលមានខ្លឹមសារជាអាទិ៍ថា " កូរ៉ុមប្រាំពីរភាគដប់ ត្រូវយកមកប្រើសម្រាប់ការអនុម័តយកសម្លេងពីរភាគបី និងកូរ៉ុមប្រាំមួយភាគដប់ ត្រូវយកមកប្រើសម្រាប់ការអនុម័តយកសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាទាំងមូល " ។

មាត្រា ១៥១ ថ្មី (មាត្រា ១៣២ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា "ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។"

មាត្រា ១៥២ ថ្មី (មាត្រា ១៣៣ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា " ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។"

មាត្រា ១៧ នៃរដ្ឋធម្មនុញ្ញបានចែងថា " ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានជាដាច់ខាត ។"

មាត្រា ១៥៣ ថ្មី (មាត្រា ១៣៤ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា "ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរី ពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។"

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣, E-mail: sgcc@camnet.com.kh

តាមការពិនិត្យលើសេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ ឃើញថា ពុំមានអ្វីប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ ។ ម្យ៉ាងទៀត ការស្នើធ្វើវិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ ថ្មីនៃរដ្ឋធម្មនុញ្ញ ធ្វើឡើងក្នុងកាលៈទេសៈធម្មតារបស់ប្រទេសជាតិ ។

២- ក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានសង្កេតឃើញថា ការធ្វើវិសោធនកម្មតែមាត្រា ៨៨ និងមាត្រា ១១១ ថ្មីនៃរដ្ឋធម្មនុញ្ញ ដើម្បីសម្រួលកូរ៉ុមសម្រាប់ការប្រជុំស្ថាប័ននីតិបញ្ញត្តិទាំងពីរ ក៏នៅមានបញ្ហាសេសសល់មួយចំនួនដូចខាងក្រោម :

ក- ការអនុម័តយកតាមសម្លេងភាគច្រើនបីភាគបួន ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ៥ នៃមាត្រា ៨០ និងវាក្យខ័ណ្ឌទី ៤ នៃមាត្រា ១០៤ ថ្មី នៃរដ្ឋធម្មនុញ្ញ តើរដ្ឋសភា និងព្រឹទ្ធសភាត្រូវកំណត់កូរ៉ុមចំនួនប៉ុន្មាន ?

ខ- ការអនុម័តយកតាមសម្លេងភាគច្រើនដោយប្រៀប ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១០០ ថ្មីនៃរដ្ឋធម្មនុញ្ញ តើរដ្ឋសភាត្រូវកំណត់កូរ៉ុមចំនួនប៉ុន្មាន ?

៣- ក្រុមប្រឹក្សាធម្មនុញ្ញ យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ ថ្មីនៃរដ្ឋធម្មនុញ្ញ អាចធ្វើទៅបាន ប៉ុន្តែត្រូវគិតគូរដល់បញ្ហាសេសសល់ដូចដែលបានក្រាបថ្វាយបង្គំទូលខាងលើ ។

សូមក្រាបថ្វាយបង្គំទូល ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជាទីបំផុត ។
សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ប៊ិន ឈិន